# របាយការណ៍សង្ខេបនៃការនាំចេញអង្ករកម្ពុជា ប្រចាំខែឧសភា ឆ្នាំ២០២០ និងប្រាំខែ ដើមឆ្នាំ២០២០

# Cambodian Rice Export Summary Report

## May 2020 and 5 months of 2020


CAMBODIA RICE FEDERATION

#2C, Street 120, Sangkat Phsar Tmey II, Khan Daun Penh, Phnom Penh, Cambodia

www.crf.org.kh    info@crf.org.kh    (855) 23 559 8999


## ការនាំចេញអង្ករកម្ពុជា ក្នុងរយៈពេល ៥ខែ ដើមឆ្នាំ២០២០ ទទួលបានចំណូល ជាង ២៤១ លានដុល្លារអាមេរិក

ព្រះរាជាណាចក្រកម្ពុជាសម្រេចបានការនាំចេញអង្ករ ៣៥៦ ០៩៧ តោន ក្នុងរយៈពេល៥ខែ ឆ្នាំ២០២០ ដែលមានកំណើនជាង៤២% បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៩ ដែលការនាំចេញបានត្រឹមតែ ២៥០ ១៧២តោន។ ប្រទេសចិនបានគ្រប់គ្រងចំនួន ៣៨% នៃទីផ្សារនាំចេញរបស់កម្ពុជា បន្ទាប់គឺ បណ្តាប្រទេស នៅក្នុងអឺរ៉ុបចំនួន ៣៤% បណ្តា ប្រទេសមួយចំនួននៅក្នុងអាស៊ានមានចំនួន ១៣% និងប្រទេសផ្សេងៗ រួមមាន អូស្ត្រាលី ហ្គាប៉ុង សហរដ្ឋអាមេរិក ។ល។ មានចំនួន ១៥%។

គោលដៅទីផ្សារនាំចេញអង្ករកម្ពុជា ក្នុងរយៈពេលប្រាំខែ ឆ្នាំ២០២០

Cambodian Rice Market  Desitnations in 5 months of 2020




បរិមាណនាំចេញអង្ករកម្ពុជា ៥ខែ ដើមឆ្នាំ២០២០ តាមទីផ្សារគោលដៅ ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៩

Cambodian Rice Export Destinations Statistic
5 months of 2020 VS 5 months of 2019




## Cambodia earns more than USD 241 million from 5 months of rice export in 2020

In 5 months of 2020, Cambodia exports rice in the total amount of 356,097 tonnes from 5 months rice export in 2020, increased by 42% comparing to the same period in 2019, which exported in the amount of 250,172 tonnes only.

In term of market destinations, China is the main source of Cambodian rice export, representing 38% of the total, followed by EU (34%), ASEAN (13%), and other destinations such as Australia, Gabon, USA, take the remainder (15%).

ទោះបីអង្ករកម្ពុជាត្រូវបង់ពន្ធនាំចូលលើទឹកប្រាក់ចំនួន ១៥០ អឺរ៉ូ ក្នុង មួយតោនក៏ដោយ ក៏កំណើននាំចេញទៅសហគមន៍អឺរ៉ុប មានសន្ទុះឡើងខ្ពស់ជាង៥១%។ ប្រទេសបារាំងជាប្រទេសដែល នាំចូល ធំជាងគេបង្អស់ គឺមាន បរិមាណជាង ៤៥ ០០០តោន បន្ទាប់គឺ ប្រទេសហូឡង់ ១៤ ៦៦៦តោន ហើយលំដាប់លេខ៣ គឺប្រទេស អង់គ្លេសជាង៩៧០០តោន បណ្តាប្រទេសនៅក្នុង អាស៊ាន ជាពិសេស ម៉ាឡេស៊ី ព្រុយណេ និងសិង្ហបុរី មានជាង ៤៥% បណ្តាប្រទេសផ្សេងៗមានចំនួន ៧៩% ហើយប្រទេស ចិនមានកំណើន ២៥% ផងដែរ។

Despite the 150 Euros/1MT of safeguard tariffs on Cambodian rice export to EU, Cambodian still exports rice increasingly to EU by 51%. In term of market destinations, France is the main source of Cambodian rice export, generating in the amount of 45,000 tonnes, followed by Holland 14,666 tonnes, England (over 9700 tonnes), ASEAN countries such as Malaysia, Brunei, Singapore increased by 45%, and other destinations increased by 79%, and last but not least is China, which is increased by 25%.

## ការនាំចេញអង្ករកម្ពុជា តាមប្រភេទផ្សេងៗ ប្រៀបធៀប ៥ខែ ឆ្នាំ២០២០ ទៅនឹង៥ខែ ឆ្នាំ២០១៩

Cambodian Rice Export by Varieties
5 months of 2020 Vs 5 months of 2019




For this 5 months of export, over 270,000 tonnes or 77% are fragrant rice, followed by white rice (18%), and the remainders are organic rice, parboiled rice, and glutinous rice. In term of percentage increase, fragrant rice is increased by 31%, while white rice is increased by 79%, generating in the amount of 62,779 tonnes, comparing to the 5 months export of 2019 is only 34,989 tonnes. Organic rice export in 5 months of 2020 is also increase by 24% comparing to the 5 months of 2019.

ការនាំចេញរបស់កម្ពុជាក្នុងរយៈពេល ៥ខែ គឺជាង ២៧ម៉ឺនតោន ឬ ៧៧% ជាប្រភេទអង្ករក្រអូប ហើយ១៨% ជាប្រភេទអង្ករស ក្រៅពីនោះជាង ៥% ជាអង្ករសរីរាង្គ អង្ករចំហុយ និងអង្ករដំណើប។ យើងឃើញថា កំណើននាំចេញក្នុងរយៈពេល ៥ខែ នេះដែរ គឺអង្ករ ក្រអូបមានកំណើនជាង ៣១% តែ អង្ករស មានកំណើនជាង ៧៩% ៦២ ៧៧៩ តោន ដែល៥ខែ ឆ្នាំ២០១៩ មានត្រឹមតែ ៣៤ ៩៨៩តោន ប៉ុណ្ណោះ។ អង្ករសរីរាង្គក៏មានកំណើននាំចេញល្អ ផងដែរ គឺមានកំណើន ជាង ២៤% ប្រៀបធៀប ទៅនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៩។

## ការនាំចេញអង្ករកម្ពុជា តាមប្រភេទផ្សេងៗ ក្នុងរយៈពេល ៥ខែ ឆ្នាំ២០២០

Cambodian Rice Export By Verieties for 5 months of Year 2020



សម្រាប់ទីផ្សារខែឧសភា ឆ្នាំ២០២០ សហគមន៍អឺរ៉ុបមានការនាំចេញរហូតដល់ជាង ២៤ ០០០តោន ឬ ៤៤% នៃចំណែកទីផ្សារនាំចេញរបស់កម្ពុជា ដែលការនាំចេញ នេះភាគច្រើនស្ទើរតែ១០០% អង្ករក្រអូប អង្ករសរីរាង្គ និងអង្ករចំហុយ ហើយកម្ពុជាក៏បាននាំ ចេញទៅប្រទេស ចិនប្រមាណជាជាង ១៤ ០០០ តោន ឬ ២៦% នៃ ចំណែកទីផ្សារនាំចេញអង្កររបស់កម្ពុជា។ កំណើនមធ្យម នៃការនាំចេញ គឺបណ្តាលមកពីការផ្អាកការនាំចេញ អង្ករសមួយរយៈ តែកំណើននៅប្រទេសចិនមានកម្រិត ប្រហាក់ប្រហែលសហគមន៍អឺរ៉ុប នឹងចាប់ ផ្តើមកើននៅខែ បន្ទាប់ ។ កំណើននាំចេញទៅបណ្តាទីផ្សារផ្សេងៗ ដូចជា ហ្គាបុង អូស្ត្រាលី រុស្ស៊ី និង ញ៉ូសាឡែន ក៏មានកំណើនខ្ពស់ គួរឱ្យចាប់អារម្មណ៍ផងដែរ។

## គោលដៅទីផ្សារនាំចេញអង្ករកម្ពុជា ក្នុងខែឧសភា ឆ្នាំ២០២០

Cambodian Rice Market  Desitnations in May 2020

បរិមាណនាំចេញសរុប ៖ ៥៥៨៤៥ តោន

Total export: 55,845 Tonnes




## ការនាំចេញអង្ករកម្ពុជា តាមប្រភេទផ្សេងៗ ក្នុងខែឧសភា ឆ្នាំ២០២០

Cambodian Rice Export By Verieties in May 2020

បរិមាណនាំចេញសរុប ៖ ៥៥៨៤៥ តោន

Total export: 55,845 Tonnes




In term of market destinations in May 2020, European Union (EU) is the main source of Cambodian rice export, generating in the amount of over 24,000 tonnes, accounted by 44% of the overall export. In term of rice varieties, almost 100% of export to EU are fragrant rice, organic rice, and parboiled rice. Cambodia export rice to China in the amount of over 14,000 tonnes, accounted by 26% of the overall. The slightly increase of export is that because of white rice export suspended for a while. However, the export to China is still increased and quite similar to EU, and will be highly increase in the following months. The export to Gabon, Australia, Russia, and New Zealand are also noticeably increased.

For rice export by varieties in May 2020, 88% are fragrant rice, 6% are white rice. White Rice is decreased by 56% comparing to May 2019, due to the white rice suspended for a while responding to the COVID19 pandemic.

សម្រាប់ប្រភេទអង្ករដែលនាំចេញក្នុងខែឧសភា ឆ្នាំ២០២០ គឺ ៨៨% ជាអង្ករក្រអូប ហើយ ៦% ជាប្រភេទអង្ករស។ អង្ករស ថយចុះ៥៦% បើ ប្រៀបធៀបទៅនឹងខែឧសភា ឆ្នាំ២០១៩ ដោយសារការផ្អាកការនាំចេញ អង្ករស មួយរយៈក្នុងរដូវកាលនៃការរីករាលដាលជំងឺកូវីដ១៩៕

**សហព័ន្ធស្រូវអង្ករកម្ពុជា** (Cambodia Rice Federation)

ប្រធានក្រុមប្រឹក្សាភិបាល (Chairman) ៖ លោកឧកញ៉ា ហ៊ុន ឡាក់ (Oknha Hun Lak)

ប្រធានសហព័ន្ធ (President) ៖ លោកឧកញ៉ា សុង សារ៉ន (Okhna Song Saran)

អគ្គលេខាធិការ (Secretary General) ៖ លោក លន់ យ៉េង (Mr. Lun Yeng)

ដកស្រង់ និងវិភាគដោយ (Cited and Analysed by)៖ លោក លន់ យ៉េង- អគ្គលេខាធិការ (Mr. Lun Yeng )

រចនាដោយ (Designed by) ៖ កញ្ញា សន ឆវីវតី - មន្ត្រីសម្របសម្រួលទំនាក់ទំនង (Ms. Sorn Chhorvyvatey - Communication Coordinator)



ប្រភពទិន្នន័យ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា Source: Ministry of Agriculture Forestry and Fisheries, and General Department of Customs and Excise